# ព្រះពុទ្ធសាសនា និង សេដ្ឋកិច្ច
## BUDDHISM & ECONOMIC

នៅក្នុងគម្ពីរព្រះពុទ្ធសាសនា មានពុទ្ធភាសិតនិងខ្លឹមសារធម៌ជាច្រើនកន្លែងដែលបញ្ជាក់ថាព្រះពុទ្ធអង្គយកចិត្តទុកដាក់ទៅលើបញ្ហាសេដ្ឋកិច្ចយ៉ាងខ្លាំង។ ជាក់ស្តែងពុទ្ធភាសិតមួយឃ្លាដែលព្រះពុទ្ធអង្គបញ្ជាក់ថា " **សព្វេ សត្តា អាហារដ្ឋិតិកា**" ប្រែថា" សត្វទាំងឡាយរស់នៅបានដោយសារអាហារ" ។ គ្រាន់តែប្រយោគមួយឃ្លានេះ បញ្ជាក់អត្ថន័យយ៉ាងទូលំទូលាយនូវបញ្ហាក្រពះ ការរស់រានមានជីវិត និងស្ថេរភាពសង្គម។ បញ្ហាក្រពះគឺការហូបចុកចិញ្ចឹមជីវិតជារៀងរាល់ថ្ងៃ មានបាយ ទឹក ផ្លែឈើ នំ ចំណី ជាដើម ដើម្បីញុំាំសារពាង្គកាយអោយប្រព្រឹត្តទៅបានតាមអត្តភាពនៃសរីរៈវិទ្យា។ ការរស់រានមានជីវិតគឺការរស់នៅប្រកបដោយភាពសុខដុមរមនា ដោយអាស្រ័យទៅលើបច្ច័យសំខាន់ៗទាំងឡាយបួនយ៉ាងគឺ: ១.ចីវរបច្ច័យ គឺសំលៀកបំពាក់បិទបាំងរាងកាយ ការពារកំដៅ អាកាសធាតុត្រជាក់ មូស របោម ធុលី និងបិទបាំងរាងកាយអោយមានភាពថ្លៃថ្នូរក្នុងភាពជាមនុស្ស, ២.បិណ្ឌបាតបច្ច័យ គឺអាហារហូបចុកប្រចាំថ្ងៃ បំពេញក្រពះអោយមានកំឡាំងពលំមាំមួន, ៣.សេនាសនៈបច្ច័យ គឺទីស្នាក់អាស្រ័យ ផ្ទះសំបែង វត្តវាអារាមស្ពាន ផ្លូវថ្នល់ រថយន្ត ដែលជាទីជំរកបិទបាំងភ្លៀងផ្គរខ្យល់និងសត្វអសិរពិសផ្សេងៗ ឬទីដើរ ទីឆ្លង និងការធ្វើដំណើរ, ៤.គិលានភេសជ្ជៈបច្ច័យ គឺថ្នាំរក្សារោគ ការបង្កើតអោយមានសុខាភិបាលល្អ បញ្ហាសុខភាពកំឡាំងកាយ កំឡាំងខួរក្បាល។ ស្ថេរភាពសង្គម គឺសំដៅលើសុខសន្តិភាព មានការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍន៍ បូរណភាពទឹកដី មានការគោរពច្បាប់ និងសហសាមគ្គីធម៌ប្រជាជាតិជនរួមឈាមតែមួយ ។

ហេតុអ្វីបានជាសេដ្ឋកិច្ចរីកចំរើន ធ្វើអោយប្រទេសជាតិនីមួយៗមានស្ថេរភាពនិងសុខសន្តិភាព ព្រោះការហូបចុកមិនគ្រប់គ្រាន់ឬការមិនមានគ្រឿងអាស្រ័យដែលជាបច្ច័យសំខាន់ៗទាំងបួននោះ ធ្វើអោយប្រជាជនគ្មានសុឆន្ទៈ គ្មានឧត្តមគតិ គ្មានកំឡាំងសតិបញ្ញា ក្នុងការគិតគូរបញ្ហាស្រុកទេស បញ្ហាសង្គមជាតិ។ ពីមួយថ្ងៃទៅមួយថ្ងៃសំរេកឃ្លាននៃក្រពះមានកាន់តែខ្លាំងឡើង កំឡាំងកាយកាន់តែចុះខ្សោយ អាហារហូបចុកគ្មានជីវជាតិគ្រប់គ្រាន់ ធ្វើអោយសតិបញ្ញាមិនឆ្លាតវាងវៃ។ ដូច្នេះធ្វើអោយមនុស្សខូចឆ្លៀតឱកាសប្រព្រឹត្តអំពើពុករលួយ ប្រើល្បិចកលបោកបញ្ឆោត ប្រព្រឹត្តអំពើវិច្ឆេទកម្មនិងវិទ្ធង្សនាផ្សេងៗ បំភិតបំភ័យ គំរាមគំហែងបំបាក់ស្មារតីប្រជាពលរដ្ឋមិនអោយគិតគូរពីការរើបំរាស់ ទាមទារតវ៉ា ដើម្បីយកសិទ្ធិនិងឯករាជម្ចាស់ការសំរាប់ខ្លួន ក្រុមគ្រួសារខ្លួន និងកូនចៅជំនាន់ក្រោយរបស់ខ្លួន ។

បច្ច័យទាំងបួន គឺគ្រឿងអាស្រ័យចំបាច់សំរាប់ការរស់នៅរបស់មនុស្សម្នាក់ៗ ដែលគ្រឿងបច្ច័យទាំងបួននោះ ព្រះពុទ្ធអង្គបានប្រកាស និង ជំរុញអោយអ្នកមានតួនាទីដឹកនាំប្រទេស ប្រឹងប្រែងខ្នះខ្នែងរកមក

ជូនប្រជាជនរបស់ខ្លួនអោយបាន។ ព្រះអង្គប្រកាសចាប់តាំងពី ២៥៤៧ ឆ្នាំកន្លងទៅហើយ តែទ្រឹស្តីសេដ្ឋកិច្ចជាមូលដ្ឋាននេះ ត្រូវបានបដិបត្តិនិងលើកស្ទួយយ៉ាងទូលំទូលាយនៅក្នុងប្រទេសដែលមានការអភិវឌ្ឍន៍ទាំងឡាយនៅលើសកលលោក។ ទ្រឹស្តីបច្ច័យបួននេះ ប្រទេសធំៗដែលមានសេដ្ឋកិច្ចរីកចំរើនទាំងឡាយនោះហៅឈ្មោះថាវេលហ្វៀ(welfare)ដែលប្រជាជនដែលអាចទទួលបាននូវវេលហ្វៀនេះ ចាត់ទុកថាជាអ្នកក្រីក្រនិងអសមត្ថភាព នៅក្នុងសង្គមរបស់គេ ដូចជាអ្នកគ្មានការងារធ្វើ ស្ត្រីមេម៉ាយ ជនពិការ ក្មេងកំព្រាទុរគត។ វេលហ្វៀនេះ ឧបត្ថម្ភតែបច្ច័យបួនតាមទស្សនៈរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់តែប៉ុណ្ណោះ គឺជួយសង្គ្រោះអោយមានសំលៀកបំពាក់គ្រប់គ្រាន់ មានម្ហូបអាហារ មានផ្ទះសំបែងស្នាក់អាស្រ័យ និង ថ្នាំសង្កូវព្យាបាលជំងឺដោយឥតគិតថ្លៃ។ ឃើញថាប្រទេសរីកចំរើនខាងសេដ្ឋកិច្ច និងមាននយោបាយតាមបែបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សទាំងនោះ បដិបត្តិទ្រឹស្តីសេដ្ឋកិច្ចមូលដ្ឋានតាមទស្សនៈរបស់ព្រះពុទ្ធសាសនាទាំងស្រុង ។ ដូច្នេះពាក្យថាវេលហ្វៀ យើងអាចប្រែជាភាសាខ្មែរបានយ៉ាងត្រួសៗថា “ សុខមាលភាព ឬ តំរូវការចាំបាច់របស់ជីវិត” ។

## សេដ្ឋកិច្ចគឺប្រយោជន៍ ៣ យ៉ាង

ពាក្យថាអត្ថៈ ប្រែថា ប្រយោជន៍ ដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានសំដែងទុកក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ចូឡវគ្គៈ ថា ការដែលអោយជីវិតរបស់យើងមានគោលដៅច្បាស់លាស់ និងអាចធ្វើដំណើរទៅកាន់គោលដៅនោះបាន លុះត្រាតែយើងដឹងនូវប្រយោជន៍ទាំងឡាយបីយ៉ាងនេះ។ ប្រយោជន៍ទាំងបីយ៉ាងនោះគឺ :

១.**ទិដ្ឋធម្មិកត្ថៈ** គឺប្រយោជន៍បច្ចុប្បន្នឬប្រយោជន៍បណ្តោះអាសន្ន ដែលយើងមានជីវិតនៅក្នុងឆាកជីវិតនេះ។ ជាប្រយោជន៍ថ្នាក់ដំបូងដែលយើងម្នាក់ៗត្រូវតែបំពេញ បង្កើតនិងបង្កើនអោយខាងតែបាន។ ប្រយោជន៍នោះមានដូចជា :

- **ឧដ្ឋានសម្បទា**គឺសេចក្តីព្យាយាមក្នុងការធ្វើការងារ ស្វែងរកចំណូលចិញ្ចឹមគ្រួសារ ប្រកបមុខរបរសុចរិត សិក្សារកចំណេះដឹងជំនាញឯកទេសខ្លួនឯង ចេះប្រើបញ្ញាដោះស្រាយបញ្ហាចិញ្ចឹមក្រពះអោយបានសំរេចផលល្អ។ សំរាប់ថ្នាក់ដឹកនាំរដ្ឋ ត្រូវតែព្យាយាម ខិតខំប្រឹងប្រែងអោយប្រជាជនរបស់ខ្លួនមានការងារធ្វើ ដោយទំនាក់ទំនងអ្នកជំនួញបរទេសឬអ្នកមានលុយកាក់ច្រើន ចូលមកវិនិយោគទុករកស៊ី បង្កើតរោងចក្រសហគ្រាស ឬរកទីផ្សារអោយមានការពង្រីកសក្តានុពលទំនិញកសិកម្មរបស់ប្រជាជន ជាផ្នែកមួយអោយមានការជាំរុញដុះរីកដុះដាលគ្រប់ភូមិស្រុកនិងគ្រួសារនីមួយៗ ។

- **អារក្ខសម្បទា** គឺសេចក្តីព្យាយាមថែរក្សាទ្រព្យសម្បត្តិលុយកាក់ដែលខ្លួនរកបានមក ដោយមិន

យកទៅចាយវាយខ្ជះខ្ជាយ ឬឈ្លក់វង្វេងដោយអបាយមុខទាំងឡាយមានស្រីស្រាល្បែងភ្នាល់ជាដើម ។ ចំណែកមេដឹកនាំរដ្ឋឬរដ្ឋាភិបាលត្រូវចេះប្រមូលទុកថវិកាដែលបានពីការទារពន្ធដារឬសម្បត្តិរួមដែលយើងហៅថាសម្បត្តិជាតិដូចជាការលក់ព្រៃឈើ រ៉ែត្បូង ត្រីជាដើម ចូលទៅក្នុងថវិកាជាតិ ទុកគ្រាន់យកមកបើកប្រាក់ខែអោយគ្រូ មន្ត្រីរាជការ និងមួយចំនួនទៀតយកទៅសាងសង់ ជួសជុលផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីររាជការ មន្ទីរពេទ្យជាដើម ឬទុកសំរងប្រើប្រាស់ពេលសេដ្ឋកិច្ចជាតិជួបតំហយចុះ ។

- **កល្យាណមិត្តតា** គឺចេះសេពគប់មិត្តល្អ មិត្តដែលនាំប្រយោជន៍មកឱ្យមិត្ត មិត្តដែលមានមេត្តាព្រហ្មវិហារធម៌ចំពោះមិត្ត មិត្តដែលស៊ូស្លាប់រស់ដើម្បីមិត្ត។ ការសេពគប់មិត្តជាកត្តាចំបងមួយ ក្នុងការធ្វើជីវិតរបស់យើងអោយចំរើនរុងរឿងថ្កុំថ្កើង ឬវិនាសហិនហោច។ ដូចគ្នាដែរ មេដឹកនាំរដ្ឋឬរដ្ឋាភិបាល ត្រូវតែសេពគប់មិត្តល្អ មិត្តដែលមានបំណងល្អចំពោះបូរណភាពទឹកដីនិងប្រជាជនខ្មែរ។ មិត្តដែលមានបទពិសោធន៍ច្រើនក្នុងការគោរពច្បាប់ គោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ។ សូមបញ្ជាក់ថាព្រះពុទ្ធសាសនាជាមេពុម្ពសំខាន់ ក្នុងការនាំមុខគេអោយមានការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ។

- **សមជីវិតា**គឺការចិញ្ចឹមជីវិតសមរម្យទៅតាមអត្តភាពខ្លួនឯង បរិដ្ឋានសង្គមនិងច្បាប់រដ្ឋ។ ការចិញ្ចឹមជីវិតត្រឹមត្រូវ មិនប្រកបមុខរបរខុសមានដូចជាធ្វើជំនួញសាច់ ជំនួញមនុស្ស ជំនួញគ្រាប់អាវុធរំសេវ និងជំនួញថ្នាំពិស គ្រឿងញៀនឬថ្នាំពេទ្យក្លែងក្លាយ។ ការចិញ្ចឹមជីវិតត្រឹមត្រូវនិងបំពេញនាទីរៀង២ខ្លួនអោយបានខ្ជាប់ខ្ជួន គឺជាវិធីតែមួយគត់ធ្វើឱ្យសេដ្ឋកិច្ចគ្រួសារនិងសេដ្ឋកិច្ចជាតិមានការរីកចំរើន។ ចំណែកមេដឹកនាំរដ្ឋឬរដ្ឋាភិបាលវិញគួរតែបំបាត់ឱ្យបាននូវការជំនួញខុសដូចជាការទិញដូរមនុស្ស ការលក់ដូរសព្វាវុធ ការលក់ដូរគ្រឿងញៀនជាដើម។ កត្តាទាំងនោះបើរដ្ឋាភិបាលឬមេដឹកនាំខ្លួនឯង មិនមានសុឆន្ទៈនិងធ្វើខ្លួនជាគំរូក្នុងការប្រឆាំងអំពើពុករលួយទេ ការធ្វើជំនួញខុសទាំងនោះនឹងនៅតែមានជាបន្ត ។

២. **សម្បរាយិកត្ថៈ** គឺប្រយោជន៍ខាងមុខឬប្រយោជន៍ដែលមានកំរិតកាន់តែខ្ពស់ឡើង។ ការដែលយើងមានសម្បរាយិកត្ថៈ ជាហេតុធ្វើឱ្យប្រយោជន៍ទិដ្ឋធម្មិកត្ថៈមានភាពឋិតថេរ រឹងមាំ និងធ្វើឱ្យប្រយោជន៍ខាងមុខទៀតមានភាពភ្លឺស្វាងល្អ។ ប្រយោជន៍ទាំងបួននោះមានអង្គប្រកបបួនយ៉ាងគឺ :

- **សទ្ធាសម្បទា**គឺសេចក្តីជឿជាក់ទៅលើសមត្ថភាពខ្លួនឯង ជឿជាក់ទៅលើភាពបរិសុទ្ធិនិងសុឆន្ទៈរបស់ខ្លួនឯង ជាពិសេសគឺជឿជាក់ទៅលើអំពើរបស់ខ្លួនឯងថា ធ្វើល្អច្បាស់ជាទទួលបានផលល្អនិងធ្វើអាក្រក់ច្បាស់ជាទទួលបានអាក្រក់។ សទ្ធាក្នុងព្រះពុទ្ធសាសនាមិនមែនជាជំនឿដូចសាសនាដទៃទេ ព្រោះជំនឿរបស់សាសនាដទៃជានិច្ចជាកាលច្រើនស្ថិតលើការបួងសួង ជឿជាក់ទៅលើវត្ថុនៅក្រៅខ្លួនថា មានមហិទ្ធិឫទ្ធិអស្ចារ្យអាចជួយសង្គ្រោះនិងការពារខ្លួនបាន ដែលជំនឿនេះមានលក្ខណៈជាអរូបិយ៍ជំនឿតាមទស្សនៈរបស់ខ្មែរយើង។ សទ្ធាក្នុងព្រះពុទ្ធសាសនាគឺច្រើនសំដៅទៅលើសុឆន្ទៈ ការតាំងសច្ចាបណិធានក្នុងចិត្ត ធ្វើអ្វីអោយពិតប្រាកដជាក់លាក់ មិនមើលបំណាំ មិនដាក់ធុរៈ មិនខ្ជិលច្រអូស ខិតខំប្រឹងប្រែងធ្វើលុះត្រាតែបានសំរេច ដោយ

អាស្រ័យទៅលើការត្រិះរិះពិចារណាជាប់ជានិច្ច មានសតិបញ្ញាជាគ្រឿងឧបករណ៍ក្នុងការយកជ័យជំនះនូវរាល់កិច្ចការទាំងអស់នោះ ។ ធ្វើអ្វីក៏ដោយ បើមនុស្សយើងខ្វះការពិចារណា ខ្វះសតិបញ្ញាហើយ មិនអាចធ្វើបានសំរេចនិងទទួលបានលទ្ធផលល្អឡើយ ជាពិសេសបញ្ហាសេដ្ឋកិច្ចនេះតែម្តង ។

– **សីលសម្បទា** គឺមានសីលធម៌ជាគ្រឹះស្ថានក្នុងការបំពេញកិច្ចការទាំងពួង ។សីលមានន័យថាការសង្រួមកាយនិងវាចា ។ កាយគឺការវៀរចាកប្រព្រឹត្តកាយទុចរិត៣យ៉ាងមានដូចជាការសំលាប់ជីវិត ការលួចប្លន់ទ្រព្យសម្បត្តិឬកិបកេងប្រវ័ញ្ចពុករលួយ និងប្រព្រឹត្តខុសផ្លូវកាម ដែលជាមនុស្សក្រាស់ទៅដោយកាមកិលេស។ ចំណែកវចីទុច្ចរិតមាន៤គឺ ការមិននិយាយកុហក់ មិននិយាយញុះញង់ចាក់ដោតឱ្យគេបែកបាក់គ្នា ការមិននិយាយពាក្យអសុរស និងមិននិយាយពាក្យរោយរាយឥតប្រយោជន៍ ។ សីលជាមូលដ្ឋានធ្វើឱ្យមនុស្សបរិបូរទាំងកិត្តនាមនិងកិត្តិយស ។ អ្នកខ្លះមានកិត្តនាមតែគ្មានកិត្តយស ព្រោះបុគ្គលនោះមិនមានហិរិឱត្តប្ប:គឺមានន័យថាជាមនុស្សមិនខ្មាសបាបនិងមិនខ្លាចបាប ឧទាហរណ៍ដូចជាមានមហិច្ឆតាចង់បានអំណាច មានសេចក្តីលោភលន់ចង់បានទ្រព្យសម្បត្តិដោយមិនគិតថាអំណាចនិងទ្រព្យសម្បត្តិនោះបានមកដោយវិធីណា ។

– **ចាគសម្បទា** គឺដល់ព្រមដោយការលះបង់ ពលីកម្ម និងមានទឹកចិត្តទូលំទូលាយ ។ មិនធ្វើជាមនុស្សមានចិត្តកំណាញ់ មិច្ឆារិយ:ជំពាក់ជក់ជាប់អារម្មណ៍ ។ ការធ្វើទានគឺការដែលយើងចេះជួយសង្គ្រោះគ្នាទៅវិញទៅមក ដោយតាមរយះរបស់របរ និងពាក្យដំបូន្មានល្អៗ ។ ការដែលយើងជួយគ្នាដោយរបស់របរហៅថាអាមិសទាន បើយើងជួយគ្នាដោយពាក្យដំបូន្មានល្អៗ យើងហៅថាធម្មទាន ។ ប៉ុន្តែទានមួយទៀតដែលយើងគួរមាននៅក្នុងចិត្តរៀងៗខ្លួនគឺអភ័យទាន មានន័យថាការចេះអនុគ្រោះអត់អោន អោយអហោសិកម្មរវាងគ្នាទៅវិញទៅមក ។

– **បញ្ញាសម្បទា** គឺការយកគំនិតពិចារណាមកធ្វើជាគោលការណ៍ក្នុងការធ្វើកិច្ចការផ្សេងៗ មិនមែនធ្វើដោយកំហឹងទល់កំហល់ ធ្វើដោយខ្វះវិចារណញាណ ។ បញ្ញាគឺជាកត្តាតែមួយគត់ដែលអាចនាំយើងទាំងអស់គ្នាទៅរកការស្វែងរកពន្លឺជោគជ័យនិងសិរីមង្គល ។ ព្រះពុទ្ធជាម្ចាស់បង្រៀននៅទីណា ទេសនាប្រៀនប្រដៅពុទ្ធបរិស័ទនៅទីណាក៏ដោយ មានគោលដៅតែមួយគត់គឺចង់អោយពុទ្ធបរិស័ទនិងអ្នកស្តាប់ទាំងអស់មានសតិបញ្ញា ។ បញ្ញាជាពន្លឺបំភ្លឺមាគ៌ាជីវិតនិងសង្គម ដែលពន្លឺនេះភ្លឺជាងអ្វីៗទាំងអស់នៅក្នុងលោកយើងនេះ ។ ដូចដែលពាក្យខ្មែរយើងពោលថា ពន្លឺព្រះអាទិត្យភ្លឺតែពេលថ្ងៃ ពន្លឺព្រះចន្ទ័ភ្លឺតែពេលយប់ ពន្លឺចង្កៀងភ្លឺតែពេលយើងអុជ តែពន្លឺនៃបញ្ញាភ្លឺទាំងយប់ ភ្លឺទាំងថ្ងៃ និងភ្លឺនៅគ្រប់ច្រកល្ហកទាំងអស់ ។ ដូច្នេះការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារក៏ដូចជាសេដ្ឋកិច្ចជាតិ ទាមទារអោយអ្នកផលិត និងអ្នកបរិភោគមានសតិបញ្ញា ។ សំរាប់មេដឹកនាំរដ្ឋឬរដ្ឋាភិបាល ត្រូវតែឆ្លាតក្នុងការធ្វើពាណិជ្ជកម្ម ធ្វើសេដ្ឋកិច្ចទីផ្សារសេរី ទាំងបែបសេដ្ឋកិច្ចធុនតូច (micro economic) ឬសេដ្ឋកិច្ចធុនធំ(macro economic) ។ ជាពិសេសមេដឹកនាំថ្នាក់ជាតិត្រូវតែ

យកចិត្តទុកដាក់អោយបានខ្លាំងទៅលើការសិក្សាអប់រំយុវជនខ្មែរអោយក្លាយទៅជាធនធានមនុស្សដ៏មានប្រសិទ្ធិភាព សំរាប់គំរោងការរយៈខ្លីនិងរយៈវែង ។

៣. **បរមត្ថៈ** គឺប្រយោជន៍ខ្ពស់បំផុត ប្រយោជន៍ដ៏ក្រៃលែង។ ប្រយោជន៍ខ្ពស់បំផុតនេះមានព្រះនិព្វានជាគោលដៅ។ ព្រះនិព្វានមិនមែនប្រែថា ស្លាប់ សោះសូន្យទទេនោះទេ ព្រះនិព្វានគឺជាសេចក្តីសុខដ៏ឧត្តម ហៅថាព្រះបរមសុខ។ ព្រះនិព្វានអាចបែងបានជាពីរគឺព្រះនិព្វានបច្ចុប្បន្ននិងព្រះនិព្វាននាអនាគត។ ព្រះនិព្វានបច្ចុប្បន្ន ជំរុញអោយយើងបានសំរេចព្រះនិព្វាននាពេលអនាគត។ ការដែលយើងអភិវឌ្ឍន៍សេដ្ឋកិច្ចរីកចំរើនដល់កំពូលដោយប្រាសចាកទុច្ចរិតទាំងពួង ប្រៀបប្រដូចយើងបានសំរេចនូវព្រះនិព្វានម្យ៉ាងនោះដែរ ។

បើនិយាយសង្ខេបនិងដោយសាមញ្ញ ចំពោះប្រយោជន៍ទាំងបីនេះ តាមភាសាដែលងាយយល់មានដូចជា :

១. **ទិដ្ឋធម្មិកត្ថៈ** សំដៅទៅលើប្រយោជន៍មានដូចជា

- មានសុខភាពល្អ កាយពលរឹងប៉ឹង មានទឹកមុខញញឹមស្រស់បស់ អាយុយឺនយូរ និងប្រាសចាករោគាព្យាធិទាំងពួង ។
- មានលុយកាក់ប្រាក់កាសប្រើប្រាស់គ្រប់គ្រាន់ ដែលកើតអំពីការមានមុខរបររកស៊ីចិញ្ចឹមជីវិតច្បាស់លាស់ និងព្យាយាមធ្វើដោយសុចរិត។
- មានឋានៈខ្ពង់ខ្ពស់កិត្តិយសថ្កុំថ្កើង ព្រោះតែមានមេត្រីភាពជាទីរាប់អាននៃអ្នកទាំងពួង ។
- មានសុខដុមរមនា ដែលមានភាពកក់ក្តៅក្នុងគ្រួសារ មានវង្សត្រកូលជាទីគោរពរាប់អាននៃញាតិឆ្ងាយជិត ។

២. **សម្បរាយិកត្ថៈ** សំដៅទៅលើប្រយោជ៍មានដូចជា

- សេចក្តីកក់ក្តៅក្នុងចិត្តដ៏ជ្រាលជ្រៅដោយមានសទ្ធា មានឧត្តមគតិ
- មានមោទនាភាពក្នុងជីវិត ដោយបានប្រព្រឹត្តតែអំពើសុចរិតទៀងត្រង់
- មានសេចក្តីស្ងប់ក្នុងអារម្មណ៍ ដែលបានពលីកម្មជួយប្រយោជន៍រួមនិងសង្គមជាតិទាំងមូល
- មានសេចក្តីក្លាហាន ជឿជាក់ក្នុងចិត្តដោយមានបញ្ញាជាអាវុធ និងមានក្តីសង្ឃឹមមុតមាំនៅក្នុងភពខាងនាយដែលបានប្រព្រឹត្តតែអំពើល្អ ។

៣. **បរមត្ថៈ** សំដៅទៅលើប្រយោជន៍មានដូចជា

- មិនញាប់ញ័រអារម្មណ៍ទៅតាមការផ្លាស់ប្តូរផ្សេងៗ ព្រោះយល់យ៉ាងច្បាស់នូវច្បាប់សាមញ្ញតាគឺអនិច្ចំ ទុក្ខំ និងអនត្តតា ។

- មិនអស់សង្ឃឹមសោកសង្រេង ឬញាប់ញ័រចិត្ត ចំពោះឧបាទាន (ការជាប់ជំពាក់) ទៅលើរបស់អ្វីមួយ ។
- មានចិត្តជាសមាធិ ស្ងប់សុខ និងបីតិសោមនស្សជានិច្ច
- មានបញ្ញាការពិចារណាជាអារុធទូវរាល់ដំណោះស្រាយទៅរកវិមុត្តិសុខ

អត្ថៈឬប្រយោជន៍នេះជាពាក្យដែលយើងប្រើយ៉ាងសាមញ្ញទៅលើវិស័យសេដ្ឋកិច្ច។ ការចំណេញ ការខាត ការតំហយចុះ និងការកើនឡើង ស្ថិតនៅលើស្ថាបនិកខាងសេដ្ឋកិច្ចបានថ្លឹងថ្លែង និងមានចំណេះដឹងខាងប្រយោជន៍នេះខ្លះហើយឬនៅ។ ជាក់ស្តែងការប្រើប្រាស់ធនធានធម្មជាតិដែលមានស្រាប់ បានបំពេញភាពចាំបាច់របស់ជីវិតនៃម្ចាស់ធនធាននោះ ឬគ្រាន់តែបំពេញមហិច្ឆតាសំរាប់តែបុគ្គលមួយក្រុមតូចប៉ុណ្ណោះ។

ម្យ៉ាងទៀតប្រយោជន៍ទាំងបីនេះអាចបែងចែកបានបីយ៉ាងទៀត ទៅតាមពុទ្ធដីកាដែលសំដែងទុកនៅក្នុងគម្ពីរដដែលនោះគឺ

១. **អត្តត្ថៈ** គឺប្រយោជន៍ខ្លួនឯងដែលប្រយោជន៍នេះមិនមែនមានន័យជាអត្តទត្ថភាពបុគ្គលនោះទេ។ ការដែលមនុស្សយើងខិតខំប្រឹងប្រែង ប្រើសតិបញ្ញារបស់ខ្លួន ប្រកបមុខរបរត្រឹមត្រូវតាមសម្មាអាជីវៈ មិនកិបកេងប្រវ័ញ្ច បោកប្រាសអ្នកដទៃ ប្រយោជន៍ដែលគេទទួលបានគឺជាអំពើល្អដែលព្រះពោធិសត្វគ្រប់ព្រះអង្គតែងតែបំពេញ។ នៅក្នុងចរិយាទាំងឡាយរបស់ព្រះពុទ្ធ ព្រះអង្គរមែងបំពេញពុទ្ធចរិយាគឺការប្រព្រឹត្តឱ្យបានសំរេចជាព្រះពុទ្ធសិន ទើបព្រះអង្គបំពេញញាតិចរិយា និងលោកចរិយាជាបន្តបន្ទាប់ ។

២. **បរត្ថៈ** គឺប្រយោជន៍អ្នកដទៃ ដែលជាទូទៅបណ្ឌិតឬព្រះពុទ្ធទាំងឡាយរមែងបំពេញនូវប្រយោជន៍នេះ។ប្រយោជន៍អ្នកដទៃគឺមានន័យថា បំពេញនូវព្រហ្មវិហារធម៌មានមេត្តា ករុណា មុទិតា និងឧបេក្ខា ដែលន័យជាទូទៅគឺបុគ្គលរមែងលះបង់ប្រយោជន៍តូចចាប់យកប្រយោជន៍ធំ លះបង់សេចក្តីសុខផ្ទាល់ខ្លួនឬក្រុមគ្រួសារខ្លួន ចាប់យកសេចក្តីសុខធំគឺបរមសុខនិងព្រះនិព្វាន។ ព្រះអរហន្តនិងព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គរមែងមើលឃើញទស្សនវិស័យនេះជាកាតព្វកិច្ចចាំបាច់មួយ។ បើសំរាប់ថ្នាក់ដឹកនាំ អ្នកមានអំណាចបុណ្យសក្តិ និងទ្រព្យសម្បត្តិច្រើន បានមានទស្សនវិស័យដូចនេះដែរ ច្បាស់ជាសង្គមយើងមានការរីកចំរើននិងមានសុខមាលភាពជាក់ជាមិនខាន ។

៣. **ឧភយត្ថៈ** គឺប្រយោជន៍ទាំងពីរឬប្រយោជន៍ទាំងសងខាង មានន័យថាបំពេញទាំងប្រយោជន៍ខ្លួនឯងផងនិងប្រយោជន៍អ្នកដទៃផង។ បើយើងនិយាយទៅលើលទ្ធិនយោបាយវិញ អត្តត្ថៈគឺរបបមួយដែលយើងហៅថារបបផ្តាច់ការព្រោះចរន្តនៃសេដ្ឋកិច្ចនិងប្រយោជន៍ធំរបស់ជាតិ ស្ថិតនៅលើបុគ្គលមួយក្រុមដែលយើងហៅថាគណកម្មការកណ្តាលឬគណកម្មការអចិន្ត្រៃយ៍។ ចំណែកបរត្ថៈ គឺជាភាគសំដែងមួយដែលមិនងាយរកបានទេ មានតែបុគ្គលលះបង់មួយចំនួន ព្រះពោធិសត្វនិងព្រះពុទ្ធគ្រប់ព្រះអង្គជាដើម។ រីឯឧភយត្ថៈ

គឺអាចប្រៀបធៀបបានស្មើរតែទាំងស្រុងទៅលើលទ្ធិប្រជាធិបតេយ្យ ព្រោះយើងសង្កេតឃើញថាចរន្តសេដ្ឋកិច្ចនិងអំណាចរបស់ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ គឺស្ថិតនៅលើប្រជាជននិងតំណាងប្រជាជន (អ្នកកាន់ការរដ្ឋ) មានទំនាក់ទំនងផ្តល់សេវាកម្មអោយគ្នាទៅវិញទៅមក ក្រោមក្រិតក្រមតែមួយគឺច្បាប់កំពូលរបស់រដ្ឋ ការបដិបត្តិប្រយោជន៍ទាំងពីរនេះ គឺមានស្ថាប័នព្រះសង្ឃ ដែលចាត់ទុកថាជាស្ថាប័នសហគមន៍គំរូរបស់លទ្ធិប្រជាធិបតេយ្យ មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសមាជិក អនុគ្រោះគ្នាទៅវិញទៅមកក្រោមព្រះវិន័យតែមួយ (សូមបញ្ជាក់ថាព្រះវិន័យមានពីរគឺអនាគារិយវិន័យ ជាវិន័យសំរាប់អ្នកបួស និងអគារិយវិន័យជាវិន័យសំរាប់គ្រហស្ថ)។

## សេដ្ឋកិច្ចអចិន្ត្រៃយ៍គឺតំរូវការចាំបាច់ មិនមែនតំរូវការតាមចំណង់ទេ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់រមែងជាស់តឿនក្រើនរំលឹកដល់ព្រះភិក្ខុសង្ឃនិងពុទ្ធបរិស័ទទាំងអស់អោយមានសន្តុដ្ឋីគឺការសន្តោយក្នុងការបរិភោគ ក្នុងការនិយាយស្តី ក្នុងការប្រព្រឹត្ត និងការបដិបត្តិធម៌។ ជាពិសេសធម៌សន្តោសនេះច្រើនបញ្ជាក់ខ្លាំងទៅលើការបរិភោគ ការប្រើប្រាស់ និងការចាយវាយ ដែលជាកត្តាមួយអោយពុទ្ធបរិស័ទចេះសន្សំសំចៃ មិនប្រើប្រាស់ខ្ជះខ្ជាយ និងថ្លឹងថ្លែងរវាងចំណូលនិងចំណាយ។ម្យ៉ាងវិញទៀតជាហេតុមួយអោយមនុស្សមានការកាត់បន្ថយនូវមហិច្ឆតាលោភលន់ ចង់បានហួសប្រមាណ ហួសពីភាពចាំបាច់របស់ជីវិត។ មួយវិញទៀតតាមគំរូដ៏ល្អរបស់ព្រះភិក្ខុសង្ឃដែលស្ថិតក្រោមម្លប់នៃព្រះវិន័យតែមួយ ព្រះពុទ្ធអង្គ តែងទូន្មានឱ្យព្រះសង្ឃ រស់នៅដោយអាស្រ័យការចិញ្ចឹមជីវិតត្រឹមត្រូវ (អាជីវបារិសុទ្ធិសីល) និងការអាស្រ័យទៅលើបច្ច័យទាំងឡាយ៤ (បច្ចយសន្និសិតសីល)។ អាជីវបារិសុទ្ធិសីល គឺការចិញ្ចឹមដែលបរិសុទ្ធិរបស់ព្រះភិក្ខុសង្ឃ ទោះបីព្រះសង្ឃមានសីលខ្ពស់ហើយ ក៏ត្រូវសង្រួមក្នុងការទំនាក់ទំនងជាមួយពុទ្ធបរិស័ទមិននិយាយបញ្ចុះបញ្ចូល ដើម្បីលាភសក្ការៈរបស់ខ្លួន។ ព្រះភិក្ខុសង្ឃមិនត្រូវអួតគុណវិសេសដើម្បីទាញយកលាភសក្ការៈពីសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទឡើយ។បច្ចយសន្និសិតសីលគឺការចិញ្ចឹមជីវិតដោយអាស្រ័យចំពោះតែបច្ច័យបួនមានចីវរ ដុំបាយ កុដិ និងថ្នាំរក្សារោគ ដែលជារៀងរាល់ថ្ងៃព្រះភិក្ខុសង្ឃត្រូវតែពិចារណានូវបច្ច័យទាំងឡាយបួននេះយ៉ាងហោចណាស់អោយបានមួយថ្ងៃពីរដងគឺពេលព្រឹកនិងពេលល្ងាច។ ការពិចារណារបស់ព្រះសង្ឃមានដូចជា យថាបច្ចយំ (ពិចារណាទៅលើបច្ច័យទាំងបួននេះថាជាធាតុពិតប្រព្រឹត្តទៅដ៏សមគួរដល់បច្ច័យ ទុកជារបស់ខ្លួន របស់អញ មិនមានឡើយ), សព្វេ/សព្វានិ (ពិចារណាទៅលើបច្ច័យទាំងបួននេះថាពេលពាល់ត្រូវកាយនេះដល់ណាហើយ ក្លាយជារបស់គួរខ្ពើមរអើម), បដិសង្ខាយោ (អោយពិចារណានៅពេលកំពុងបរិភោគថាប្រើប្រាស់និងបរិភោគដើម្បីតែការពារនូវកំដៅថ្ងៃ អាកាស មូស របោម តែប៉ុណ្ណោះ មិនមែនបរិភោគដើម្បីកំឡាំង បង្កើនសំរស់ ជាអ្នករបាំ ជាអ្នកកីឡានោះទេ), រួចហើយពិចារណាដូចគ្នានេះម្តងទៀតនៅពេលបរិភោគរួច អោយសូត្របទ អជ្ជមយា ជាដើម។

ចំណែកទ្រឹស្តីរបស់អ្នកប្រាជ្ញខាងសេដ្ឋកិច្ច តែងតែអោយនិយមន័យទៅលើពាក្យសេដ្ឋកិច្ច ថា "ជាការចំរាញ់យកធនធានធម្មជាតិដែលមានស្រាប់ មកបំរើតំរូវការចាំបាច់របស់មនុស្ស" ។ យើងស្គាល់ហើយថា ធនធានធម្មជាតិដែលមានស្រាប់មានដូចជា រ៉ែក្រោមដី ព្រៃឈើលើបព្វតា ផលសារលើផ្ទៃទន្លេនិងសមុទ្រ ព្រមទាំងមច្ឆាជាតិ ព្រះធរណី ទឹក វាយោ និងកំដៅ។ ទាំងអស់នេះត្រូវបានមនុស្សស្រាវជ្រាវ កែច្នៃទៅជាវត្ថុប្រើប្រាស់ផ្សេងៗរាប់រយជំពូកនិងមានលក្ខណៈទាន់សម័យជានិច្ច ។

ហេតុអ្វីបានជាលើកបញ្ហានេះមកលាតត្រដាង ពីព្រោះចង់បញ្ជាក់ថាសព្វថ្ងៃអាស្រ័យសេដ្ឋកិច្ចមូលធននិយម ទីផ្សារសេរីគ្មានព្រំដែន ធ្វើអោយប្រទេសមួយចំនួនចង់មានបានរហូតដល់គ្មានវិចារញ្ញាណការពារបរិដ្ឋានប្រទេសខ្លួនឯង។ ប្រទេសខ្លះព្យាយាមពង្រីកអំណាចត្រួតត្រារបស់ខ្លួនទៅលើប្រទេសតូចតាចទន់ខ្សោយហើយខិតខំក្រេបជញ្ជក់យកធនធានធម្មជាតិទៅបង្កើនភាពមានបានរបស់ខ្លួន។ តំបន់ខ្លះគេដាក់ជាតំបន់ខៀវ ឬជាតំបន់អនុរក្សពិសេស។ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនព្យាយាមយកចិត្តទុកដាក់រក្សាព្រៃឈើ សត្វព្រៃ និងធនធានធម្មជាតិដទៃទៀតអោយមានតុល្យធម្មជាតិវិទ្យា ។

ការធ្វើសេដ្ឋកិច្ចតាមចំណង់របស់មនុស្សបន្សល់ទុកនូវផលប៉ះទង្គិចយ៉ាងខ្លាំងដល់មនុស្សជាតិនិងពិភពលោកទាំងមូល។ កត្តាទាំងនេះកើតពីអ្នកសេដ្ឋសាស្ត្រខ្លះបង្កើតទ្រឹស្តីសេដ្ឋកិច្ចដោយខ្វះវិចារណញ្ញាណនិងទំនួលខុសត្រូវ។ នេះជាលក្ខណៈអសីលធម៌និងបំផ្លាញកូនចៅជំនាន់ក្រោយរបស់ខ្លួន។ បើយើងសង្កេតទៅលើទ្រឹស្តីរបស់ព្រះសម្មាសម្ពុទ្ធឬអ្នកសេដ្ឋសាស្ត្រមួយចំនួន យើងនឹងឃើញការយកចិត្តទុកដាក់ទៅលើការមានតុល្យភាពរវាងអ្នកបរិភោគនិងធនធានធម្មជាតិដែលមានស្រាប់។ តុល្យាភាពនេះកើតចេញពីមនុស្សយើងត្រូវប្រើប្រាស់ទៅតាមភាពចាំបាច់នៃជីវិត មិនមែនប្រើប្រាស់ទៅតាមចំណង់តណ្ហាដែលមានមិនចេះចប់របស់មនុស្សនោះទេ ។

ក្នុងប្រទេសកម្ពុជា វិបត្តិនៃសង្គ្រាម ការមានចំណង់តណ្ហាដ៏លើសលប់របស់ក្រុមមេដឹកនាំមួយក្តាប់តូច សម្បត្តិធម្មជាតិដែលជាទុនតែមួយគត់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិអោយមានគ្រឹះរឹងមាំ បានកំពុងហិនហោចចុះជាបន្តបន្ទាប់។ កាលពីមុនទសវត្សន៍ឆ្នាំ៧០ ព្រៃឈើរបស់កម្ពុជាលាតសន្ធឹងលើផ្ទៃដី៧០ភាគរយតែសព្វថ្ងៃនេះនៅសល់ប្រហែលជា៣០ទៅ៣៥ភាគរយតែប៉ុណ្ណោះ។ បើរាប់បញ្ចូលទាំងធនធានត្រី រ៉ែត្បូងនិងព្រៃឈើ ដែលបានបាត់បង់ទៅនោះអាចជាទុនដ៏មហាសាលជួយអោយសេដ្ឋកិច្ចខ្មែរយើងមានភាពរឹងប៉ឹងនឹងគេ តែអ្វីដែលជាផលអាក្រក់មកលើប្រជាជនខ្មែរនោះ លុយកាក់ដែលគេបានពីលក់សម្បត្តិធម្មជាតិនោះក៏បាត់ ព្រៃឈើ រ៉ែត្បូង និងត្រីក៏ត្រូវដយចុះ ហើយភាពរាំងស្ងួត ទឹកជំនន់ រដូវកាលមិនទៀងទាត់បានកំពុងយាយីជីវិតប្រជាជនខ្មែរនិងកូនចៅខ្មែរជាបន្តបន្ទាប់ ។

ដូច្នេះមេដឹកនាំរដ្ឋ គួរពិចារណាគិតគូរឡើងវិញ នូវតុល្យការនៃសេដ្ឋកិច្ច ដែលជាកត្តាស្លាប់រស់នៃកូនចៅខ្មែរជំនាន់ក្រោយ និងជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចដ៏ត្រឹមត្រូវមួយ ។

## គួរវៀរចាកអបាយមុខ

សេដ្ឋកិច្ចជាតិមួយដែលល្អ គួរវៀរចាកការប្រព្រឹត្តអបាយមុខទាំង៦។ អបាយមុខប្រែថាមគ្គវិធីនាំទៅរកសេចក្ដីវិនាស។ ព្រះពុទ្ធអង្គទ្រង់សំដែងទុកក្នុងសុត្តន្តបិដក ទីឃនិកាយ បាដិគ្គវៈ ដូចតទៅនេះ

១. ជាប់អាភៀនញៀនសុរា ដែលជាហេតុនាំមកនូវនូវទោស ៦ យ៉ាងគឺ

- ទ្រព្យកាន់តែអស់រលត់ទៅ ដោយមិនដឹងខ្លួន
- បង្កអោយមានជំលោះទាស់ទែង កាប់ចាក់គ្នា
- ធ្វើអោយសុខភាពមានភាពទ្រុឌទ្រោមចុះជាលំដាប់
- ខូចដល់កិត្តិយស កេរ្តិ៍ឈ្មោះ គ្មានគេគោរពកោតខ្លាច
- ធ្វើអោយខ្លួនឯងក្លាយទៅជាមនុស្សគ្មានហិរិ-ឱត្តប្បៈ
- ខួរក្បាល និងប្រាជ្ញាចុះខ្សោយជាបន្តបន្ទាប់

២. ដើរលែងយប់ព្រលប់ជាប្រចាំ នាំអោយមានទោស ៦ យ៉ាង

- មិនមានការរក្សាខ្លួនឯង
- មិនចេះថែរក្សាប្រពន្ធកូន ថែរក្សាទ្រព្យ
- ជាទីមន្ទិលសង្ស័យរបស់ជនទូទៅ
- គេអាចចោទប្រកាន់ទោសប្រការណាមួយក៏បាន
- នាំអោយកើតការក្ដៅក្រហាយដល់អ្នកដទៃ

៣. ដើរលែងកំសាន្ត ច្រៀងរាំជាប្រចាំ ជាហេតុនាំអោយខូចបង់ទ្រព្យ ខ្សោយសុខភាព អាចឆ្លងមេរោគផ្លូវភេទមកចំឡងដល់ប្រពន្ធក្នុងគ្រួសារ

៤. ញៀននឹងល្បែងស៊ីសង ជាហេតុនាំអោយមានទោស ៦ យ៉ាង

- ពេលឈ្នះគេ រមែងមានពៀរ
- ពេលចាញ់ មានការសោកស្ដាយទ្រព្យដែលបាត់បង់ទៅ
- ទ្រព្យកាន់តែអស់ទៅៗ ឃើញយ៉ាងច្បាស់
- ជាមនុស្សដែលគេមិនទុកចិត្ត មិនជឿពាក្យសំដី
- ជាទីមើលស្រាល មើលថោករបស់ញាតិ និងមិត្តភក្តិ

៥. សេពគប់មិត្តអាក្រក់ ជាមិត្តដែលអូសទាញមិត្តទៅផឹកស្រា រាំលែងកំសាន្តជាប្រចាំ លែងល្បែងភ្នាល់ បន្លំឆបោក និងបងធំបងតូចជាដើម ។

៦. ខ្ជិលច្រអូសក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ដោយចេះតែលើកហេតុផលផ្សេងៗមកអាង ដូចជា រងារខ្លាំង ក្តៅខ្លាំង ព្រឹកពេក ល្ងាចហើយ ឃ្លានខ្លាំង ឆ្អែតពេក រួចក៏គេចវេះពីការធ្វើកិច្ចការនោះអោយរួចឆាប់រហ័ស ការងារដែលត្រូវធ្វើមួយម៉ោង ត្រូវចំណាយពេលដល់ទៅមួយថ្ងៃក៏មាន ។

អបាយមុខទាំង៦នេះ ជួនកាលអាចគិតថាមិនទាន់សម័យ តែបើពិនិត្យអោយបានល្អិតល្អន់ទៅ ធម៌នេះគឺជាក្រិតក្រមមួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច រាប់តាំងពីសេដ្ឋកិច្ចគ្រួសារដល់ទៅសេដ្ឋកិច្ចថ្នាក់ជាតិ។ សំរាប់សេដ្ឋកិច្ចថ្នាក់គ្រួសារ បើមេគ្រួសារជាមនុស្សដែលគិតតែពីផឹកស្រាញៀនបារី ចូលចិត្តរាំកំសាន្ត ដើរលែងយប់ព្រលប់ជាប្រចាំ លែងល្បែងស៊ីសង សេពគប់តែមិត្តអាក្រក់ និងខ្ជិលច្រអូសហើយ ក្រុមគ្រួសារនោះច្បាស់ជាក្រីក្រអត់ឃ្លាន កូនចៅប្រពន្ធខ្វះមុខខ្វះក្រោយសូម្បីតែសំលៀកបំពាក់បិទបាំងរាងកាយក៏គ្មាន។ ចំណែកមេដឹកនាំរដ្ឋនិងរាជរដ្ឋាភិបាលវិញ បើជៀសមិនផុតពីអបាយមុខទាំង៦នេះទេ ប្រទេសជាតិនឹងពេញទៅដោយជនពុករលួយ សេដ្ឋកិច្ចជាតិមួយភាគធំនឹងធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ជនខិលខូចជាក់ជាមិនខាន។ ជាពិសេសការបង្កើតអោយមានបនល្បែងស៊ីសង នាំអោយប្រទេសជាតិមានចោរឆក់ប្លន់និងមន្ត្រីពុករលួយ។ ការបើកអោយមានរោងក្រសាលរោងបា នាំអោយមានស្ត្រីប្រកបមុខរបរផ្លូវភេទនិងការជួញដូរមនុស្ស។ ការសេពគប់មិត្តក្រៅប្រទេសគួររកផ្លូវចំណេញខាងនយោបាយ និងខាងសេដ្ឋកិច្ចជាធំ ។ ប្រទេសមួយដែលបរិបូរទៅដោយប្រជាជននិងមន្ត្រីប្រព្រឹត្តអំពើអបាយមុខទាំង៦ខាងលើនេះ ប្រទេសនោះនឹងជួបប្រទះតែភាពក្រីក្រ បាត់បង់កិត្តិយស និងអស្ថេរភាពសង្គម ជាពិសេសភាពអនាធិបតេយ្យមិនគោរពច្បាប់ ។

## ការបែងចែកផលចំណេញខាងសេដ្ឋកិច្ចដ៏ត្រឹមត្រូវមួយ

ក្នុងសុត្តន្តបិដក ទីឃនិកាយ បាដិគ្គវគ្គៈ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងអំពីការបែងចែងផលចំណេញខាងសេដ្ឋកិច្ចជា៤ចំណែកធំៗ (ភោគវិភាគ៤) គឺ

១. មួយចំណែកយកមកប្រើប្រាស់ខ្លួនឯង ចិញ្ចឹមកូនប្រពន្ធ ក្រុមគ្រួសារ ញាតិមិត្ត និងបំពេញប្រយោជន៍សាធារណៈ ។

២. ពីរចំណែកយកទៅធ្វើជាដើមទុនរកស៊ី មានការវិនិយោគទុន ការធ្វើពាណិជ្ជកម្មជាដើម ។

៣. មួយចំណែកត្រូវរក្សាទុកប្រើប្រាស់ពេលមានគ្រោះអាសន្ន ។

យើងល្បងសិក្សាអំពីការបែងចែកទ្រព្យនេះអោយលំអិតមើល តើសមហេតុសមផលនឹងស្ថានការណ៍

បច្ចុប្បន្នទេ?។ បើនិយាយជាភាគរយយើងឃើញថា ២៥ភាគរយទុកចិញ្ចឹមជីវិតក្រុមគ្រួសារជារៀងរាល់ថ្ងៃ ៥០ភាគរយ យកទៅបណ្តាក់ទុនរកស៊ី និង២៥ភាគរយដែលនៅសល់យកទៅផ្ញើរធនាគារឬតំកល់ទុកកន្លែងណាមួយដើម្បីការពារគ្រោះអាសន្នដែលយើងមើលមិនឃើញ។ បើពិនិត្យទៅឃើញថាជាការសមរម្យណាស់ដែលយើងយកមកប្រើប្រាស់ប្រចាំថ្ងៃ២៥ភាគរយ តំកល់ទុក២៥ភាគរយ ហើយស្វែងរកបន្ថែមដោយចំណាយដល់ទៅ៥០ភាគរយ។ ទ្រឹស្តីដែលព្រះពុទ្ធទ្រង់សំដែងនេះ បញ្ជាក់នូវភាពជាអ្នកជំនួញនិងការរកមកទុកបន្ថែមជាអាទិភាពចំបងគេ។ នៅប្រទេសដែលមានការរីកចំរើនគេនឹងជួយផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃនិងតំកល់ទុកសំរាប់ឧប្បទ្ទវហេតុឬហេតុការណ៍ចៃដន្យដែលអាចកើតមានចំពោះជីវិតនិងសុខភាពសំរាប់បុគ្គលណាដែលគ្មានការងារធ្វើ។ តែការជួយនេះមានរយះពេលតែ៦ខែឬយ៉ាងយូរមួយឆ្នាំតែប៉ុណ្ណោះ គេនឹងផ្តាច់។ ដូច្នេះត្រូវតែបង្ខំចិត្តស្វែងរកការងារធ្វើអោយខាងតែបាន ដូចដែល៥០ភាគរយត្រូវតែយកទៅបណ្តាក់រកស៊ីជាអាទិភាពសំខាន់។ បើយើងសង្កេតទៅលើការគ្រប់គ្រងប្រទេស មេដឹកនាំត្រូវតែបង្ខំចិត្តរកចំណូលនិងធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចជាតិមានការវិលចុះវិលឡើងជានិច្ចសំរាប់៥០ភាគរយ សំរាប់តុល្យភាពដែលបរិភោគអស់ទៅ២៥ភាគរយ និងទុកតំកល់ក្នុងឃ្លាំងជាតិ២៥ភាគរយ។ តាមលក្ខណៈនេះ ហាក់ដូចជាបញ្ជាក់ប្រាប់យើងអោយដឹងថាព្រះពុទ្ធអង្គយកចិត្តទុកដាក់ទៅលើអនាគតយ៉ាងខ្លាំង ដែលអនាគតនោះជារឿងមិនទៀងទាត់ មានការផ្លាស់ប្តូរជាប់ជានិច្ច ដូច្នេះយើងគួរកុំប្រមាទ គួរតែយក៧៥ភាគរយនៃថវិកាដែលមានទាំងអស់ ទៅសំរិតសំរាំងប្រិតប្រៀងទុកសំរាប់អនាគត ។

ក្រៅអំពីភោគវិភាគ ព្រះពុទ្ធអង្គទ្រង់សំដែងអំពីភោគទិយៈគឺផលប្រយោជន៍ដែលកើតមកពីភោគៈដែលព្រះអង្គទ្រង់ត្រាស់ចំពោះព្រះភិក្ខុសង្ឃនៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត យ៉ាងលំអិតដែលយើងអាចយកមកល្បងវិនិច្ឆ័យនិងសិក្សាមើលនៅទីនេះ។ តាមទ្រឹស្តីភោគទិយៈនោះមានដូចជា

១. ចិញ្ចឹមខ្លួនឯង ចិញ្ចឹមមាតាបិតា ស្វាមី ភរិយា បុត្រ និងអ្នកដែលស្ថិតក្រោមការថែរក្សាថែទាំរបស់ខ្លួន ។
២. ជួយទំនុកបំរុងមិត្តសាហាយនិងអ្នករួមការងារ
៣. ប្រើប្រាស់ក្នុងការការពាររក្សាសុវត្ថិភាព ជារបងការពារខ្លួនកុំអោយមានអន្តរាយ
៤. ធ្វើពលី គឺលះបង់ដើម្បីបំរុងនិងបូជា ៥ យ៉ាង

- ញាតិពលី គឺ ការសង្គ្រោះញាតិទាំងឡាយ
- អតិថិពលី គឺ ការបដិសណ្ឋារៈភ្ញៀវទាំងឡាយ
- បុព្វបេតពលី គឺ ធ្វើបុណ្យឧទ្ទិសកុសលឬសក្ការៈដល់អ្នកដែលបាត់បង់ជីវិតទៅហើយ
- ទេវតាពលី គឺ ថ្វាយទេវតា សក្ការៈវត្ថុដែលខ្លួនគោរពបូជា

៥. ឧបត្ថម្ភព្រះសង្ឃ ឬ អ្នកបួស ដែលប្រព្រឹត្តធម៌ជាគំរូដល់អ្នកដទៃ និងជាអ្នកបង្រៀនធម៌ស្ងប់ដល់ប្រជាជនទាំងឡាយ ។

ចំណុចទាំង៥ខាងលើនេះយើងអាចយកមកប្រើសំរាប់រដ្ឋាភិបាលបានផងដែរ ដូចជាគួរតែមានថវិកាទុកសំរាប់ចិញ្ចឹមប្រជាជនរបស់ខ្លួនឯង, ទុកសំរាប់ទទួលបដិសណ្ឋារៈភ្ញៀវជាតិនិងអន្តរជាតិ, ទុកឧបត្ថម្ភដល់ប្រជាជនដែលនៅតាមជាយរបងព្រំដែន ឬសាងមន្ទីរពេទ្យ សាងវត្តអារាមនៅទីនោះ ឬឧបត្ថម្ភដល់កងទ័ពដែលយាមល្បាតនៅតាមព្រះដែន, ទុកសំរាប់ធ្វើបុណ្យទានផ្សេងៗ មានបុណ្យជាតិ បុណ្យសាសនា ឬសាងចេតិយ៍វីរជនរបស់ជាតិ ចេតិយ៍តំកល់សារីរិកធាតុអោយប្រជាជនគោរពបូជាជាដើម និងឧបត្ថម្ភដល់ព្រះសង្ឃដែលជួយអប់រំសីលធម៌ដល់ប្រជាជន និងចាស់ព្រឹទ្ធាចារ្យដែលធ្វើការងារបំរើប្រទេសជាតិកន្លងមក ។

## សេដ្ឋកិច្ចរីកចំរើនមានន័យថា ប្រជាជនទទួលបាននូវសេចក្តីសុខ ៤ យ៉ាង

ដើម្បីអោយកាន់តែច្បាស់ថា តើសេដ្ឋកិច្ចជាតិមួយដែលមានការរីកចំរើនពិតប្រាកដ អាចបំរើសេចក្តីសុខបួនយ៉ាងរបស់ប្រជាជនបានដែរឬទេ?។ នៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ព្រះសម្មាសម្ពុទ្ធបានសំដែងអំពីសេចក្តីសុខបួនយ៉ាងដែលបានអំពីសេដ្ឋកិច្ចល្អដូចតទៅនេះ

១. **អត្ថិសុខ** គឺសុខដែលកើតអំពីការមានទ្រព្យ មានសេចក្តីពេញចិត្ត ស្កប់ស្កល់ និងកក់ក្តៅក្នុងចិត្ត ដែលខ្លួនមានទ្រព្យព្រោះតែសេចក្តីឧស្សាហ៍ព្យាយាម និងបានមកដោយសុចរិតធម៌តាមសម្មាអាជីវោ។

២. **ភោគសុខ** គឺសេចក្តីសុខដែលកើតអំពីការបានប្រើប្រាស់ទ្រព្យសម្បត្តិនោះ មានសេចក្តីពេញចិត្តស្កប់ស្កល់ចិត្ត ដោយបានចិញ្ចឹមខ្លួនឯង ទំនុកបំរុងក្រុមគ្រួសារ និងឆ្លៀតជួយសង្គមបានថែមទៀតផង ។

៣. **អនណសុខ** គឺសេចក្តីសុខដែលខ្លួនបានមានទ្រព្យ បានប្រើប្រាស់ទ្រព្យ ប្រាសចាកការខ្ចីបុលគេ ដែលជាបំណុល ប្រៀបបាននឹងគ្រឿងចងភ្ជាប់ខ្លួនមិនអោយមានសេរីភាព ។

៤. **អនវជ្ជសុខ** គឺសេចក្តីសុខដែលកើតអំពីការប្រាសចាកទោសទាំងពួង មានការប្តឹងផ្តល់ ក្តីក្តាំគ្នា ឬការតិះដៀលប្រមាថមើលងាយដោយកាយ វាចា ចិត្ត ពីសំណាក់មហាជនទាំងឡាយ ។

## ឯកសារយោងសំខាន់ៗ

១. សុត្តន្តបិដក ខុទ្ទកនិកាយ ចូលវគ្គ

២. សុត្តបិដក ទីឃនិកាយ បាដិកវគ្គ

៣. សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចវគ្គ

៤. សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កវគ្គ